002/19-09-2007-ECCC/TC
E1/66

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 05 / 2012
ម៉ោង (Time/Heure): 09 : 35
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ច័ន្ទ ទី ២៣ ខែ មេសា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៥៤

រៀបចំដោយ: ដាវ អានសាន និង Andrew James MCINTYRE

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោក Andrew James MCINTYRE, លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ច័ន្ទ តារាស្មី, លោក Vincent de Wilde d'Estmael, លោក Dale LYSAK។ |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMAN, លោក Jasper PAUW។ |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS។ |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE។ |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក ឡោ ជុនធី, លោកស្រី ម៉ុច សុវណ្ណារី, លោក ហុង គីមសួន, លោក វ៉ែន ពៅ, លោកស្រី ជេត វ៉ាន់លី, លោកស្រី ស៊ិន សូវន, លោកស្រី Elisabeth RABESANDRATANA និង លោក Barnabé NEKUIE។ |
| សាក្សី៖ សាឡុត បាន (TCW-586) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ។ |
| ផ្សេងៗ៖ កញ្ញា Alexandra PRASSOLOFF, លោក លឹម ប៊ុនហេង (មេធាវីសាក្សី) |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១២ | ចាប់ផ្ដើមម៉ោង៖ ៩.០៥ | បញ្ចប់ម៉ោង៖ ១៦.០០ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៣៥ | បញ្ចប់ម៉ោង៖ ១០.៥៥ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.០០ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ | | ៤ ម៉ោង ៤៥ នាទី |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការបង្ហាញឈ្មោះមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវសួរសាក្សី | មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ | ៩.០៥ | ៩.១០ |
| បញ្ហាបញ្ជើឯកសារនៅមុនការសួរសាក្សី | ក្រុម អៀង សារី | ៩.១០ | ៩.១៥ |
| ការសួរសាក្សី សាឡុត បាន | តំណាងសហព្រះរាជអាជ្ញា | ៩.១៥ | ១៦.០០ |
| សំណើលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវី អៀង សារី<br>មេធាវី នួន ជា | ១០.៣០<br>១២.០០ | ១០.៣០<br>១២.០០ |

| | | | |
|---|---|---|---|
| ការរំឭកអំពីនីតិវិធីជំទាស់និងសំណួររបស់មេធាវីការពារក្ដី | អង្គជំនុំជម្រះ | ១៥.៤០ | ១៥.៤៥ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ កោះហៅសាក្សីចូលសវនាការ និងសាកសួរបឋមដល់សាក្សីជាមួយនឹងការប្រាប់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី។

**<u>ការបង្ហាញឈ្មោះមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវសួរសាក្សី</u>**

មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបញ្ជាក់ដល់អង្គជំនុំជម្រះថា លោកស្រី ជេត វ៉ាន់លី និង លោកស្រី Elisabeth RABESANDRATANA នឹងសាកសួរសាក្សី។ អង្គជំនុំជម្រះអនុញ្ញាតតាមសំណើជាមួយនឹងពេលវេលាដែលបានស្នើសុំកន្លងមក។

**<u>បញ្ហាបញ្ជីឯកសារ នៅមុនការសួរសាក្សី</u>**

ក្រុមអៀង សារីបង្ហាញថា ខ្លួនមិនបានទទួលបញ្ជីឯកសារ តាមប្រព័ន្ធបង្ហាញឯកសារប្រចាំថ្ងៃនៅក្នុងសវនាការ ដែលសហព្រះរាជអាជ្ញាមានបំណងប្រើប្រាស់ក្នុងការសាកសួរសាក្សីឡើយ។ សហព្រះរាជអាជ្ញាឆ្លើយតបថាខ្លួនបានប្រើប្រាស់ប្រព័ន្ធនេះដើម្បីចែករំលែកឯកសារដែលនឹងត្រូវប្រើប្រាស់។ អជសង បង្គាប់ឲ្យសហព្រះរាជអាជ្ញាផ្ដល់ឯកសារដល់ភាគី។

**<u>ការសួរសាក្សី សាឡុត បាន</u>**

សាក្សីបានស្បថរួចហើយ និងមានជំនួយដោយមេធាវីមួយរូប។ តំណាងសហព្រះរាជអាជ្ញាជាតិសួរសាក្សី សាឡុត បាន។

**<u>ការលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់</u>**

មេធាវីការពារក្ដី អៀង សារី (ម៉ោង១០.៣០នាទី) និង នួន ជា (ម៉ោង ១២) ស្នើសុំលះបង់សិទ្ធិឲ្យកូនក្ដីរបស់ខ្លួន ក្នុងការចូលរួមសវនាការដោយផ្ទាល់ ប៉ុន្តែសុំចូលរួមសវនាការពីបន្ទប់រង់ចាំខាងក្រោមបន្ទប់សវនាការ។ អង្គជំនុំជម្រះអនុញ្ញាតតាមសំណើមេធាវីការពារក្ដី អៀង សារី និងមេធាវីការពារក្ដី នួន ជា ដោយបង្គាប់ឲ្យ

មេធាវីការពារក្តីប្រគល់លិខិតលះបង់សិទ្ធិជាលាយលក្ខណ៍អក្សរជូនអង្គជំនុំជម្រះ។ ក្រុមការពារក្តី អៀង សារី និងក្រុមការពារក្តី នួន ជា បានផ្តល់លិខិតលះបង់សិទ្ធិដល់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង។

**<u>ការរំឭកអំពីនីតិវិធីជំទាស់នឹងសំណួររបស់មេធាវីការពារក្តី</u>**

មេធាវីសាក្សីលើកឡើងថា សំណួរចំពោះកូនក្តីរបស់ខ្លួនអាចជាការដាក់បន្ទុក។ អជសង ផ្តល់យោបល់ដល់មេធាវីសាក្សីធ្វើការប្រឹក្សាជាមួយកូនក្តីខ្លួនជាមុន ហើយថា វាជាការសម្រេចរបស់សាក្សីក្នុងការឆ្លើយតប។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/136 | D313/1.2.237 | P 00416593 - 00416593 P 00416593 - 00416593 P 00416593 - 00416593 | [លិខិតបញ្ជាក់ការជំនួសឯកសារ] Photograph depicting senior leaders at a Party Congress, possibly in 1971 [Surrogate Sheet] Photograph depicting senior leaders at a Party Congress, possibly in 1971 [Surrogate Sheet] Photograph depicting senior leaders at a Party Congress, possibly in 1971 | P | | | |
| E3/1595 | D313/1.2.234 | P 00416590 - 00416590 | Photograph depicting senior leaders at a Party Congress, possibly in 1971 | P | | | |
| E3/137 | D313/1.2.236 | P 00416592 - 00416592 P 00416592 - 00416592 P 00416592 - 00416592 | [លិខិតបញ្ជាក់ការជំនួសឯកសារ] Photograph depicting senior leaders at a Party Congress, possibly in 1971 [Surrogate Sheet] Photograph depicting senior leaders at a Party Congress, possibly in 1971 [Surrogate Sheet] Photograph depicting senior leaders at a Party Congress, possibly in 1971 | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/91 | D91/14 | 00204093-00204098<br>00223589-00223593<br>00503930-00503937 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត និត្យា ហៅសូវ ហុងថ្ងៃទី១១ ១២ ២០០៧<br>[Surrogate Sheet] Written Record of Interview of Saloth Ban, alias SO Hong<br>[Feuille remplacée] Procès verbal d'audition de Saloth Ban, alias SO Hong | P | 00204096, 00204095-96 | 00223592 | 00503934, 00503933 |
| E3/446 | D369/36 | 00492957-00492972<br>00503160-00503172<br>00529506-00529520 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី LOT Nitya ឡុត និត្យា/SALOT Ban សាឡុត បាន/ SO Hong ស្វរ ហុង<br>Written Record of Interview of Witness LOT Nitya ឡុត និត្យា/SALOT Ban សាឡុត បាន/ SO Hong ស្វរ ហុង<br>Procès verbal d'audition de témoin LOT Nitya ឡុត និត្យា/SALOT Ban សាឡុត បាន/ SO Hong ស្វរ ហុង | P | | Answer number 2, A4, A5, A21, A32, A37, A39, A70 | |
| E3/413 | D233/2 | 00357525-00357534<br>00361008-00361017<br>00405451-00405459 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាឡុត បាន SALOT Ban /ស្វ ហុង SO Hong ថ្ងៃទី ២២-០៧-២០០៩<br>Written Record of Interview of SALOT Ban សាឡុត បាន/SO Hong ស្វ ហុង Dated 22-07-2009<br>Procès verbal d'audition de témoin SALOT Ban សាឡុត បាន/SO Hong ស្វ ហុង en date du 22-07-2009 | P | 00357530 | 00361012 | 00405455 |

<u>**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**</u>

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ អៀង សារី និង នួន ជា ចូលរួមដំណើរការសវនាការពីបន្ទប់នៅខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ និងបង្គាប់ឲ្យមេធាវីផ្តល់លិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទ ត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១២។

| **<u>កាលបរិច្ឆេទបន្តសវនាការ៖</u>** |
|---|
| សវនាការនឹងបន្តនៅថ្ងៃ អង្គារ ទី ២៤ ខែ មេសា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ដាវ អានសាន** **Andrew James MCINTYRE**